បេះដឹងបានទេ ។ តែកាលណាគេឃើញច្បាស់លែងមានជំនឿទៀតនោះ ទើបគេអាចអះអាងថា គេបេះដឹងបាន ។ ពិតមែនតែក្នុងគម្ពីរពុទ្ធសាសនា តែងតែជួបប្រទះនឹងពាក្យបាលីថា «សទ្ធា» ហើយគេប្រែថាជំនឿ ឬការជឿ តែតាមន័យពិតរបស់ពាក្យដែលប្រើក្នុងបរិបទនេះ គឺជាទំនុកទុកចិត្ត កើតពីជំនឿស៊ប់ **អចលសទ្ធា** ដែលផុសចេញពីធម្មនិដ្ឋចំពោះព្រះពុទ្ធ, ព្រះធម៌និងព្រះសង្ឃនេះឯង ។ ពាក្យនេះមិនបានសេចក្ដីក្រៅឡើយ ទាំងទិដ្ឋភាពរបស់ពាក្យ «សទ្ធា» នេះសោតទៀត ដែលទស្សនវិទូដ៏ល្បីឈ្មោះ **អាសង្គ** កំណត់ហើយនោះ សឹងអះអាងបញ្ជាក់ថា :

១– ជំនឿស៊ប់ទាំងស្រុងយ៉ាងមុឺងម៉ាត់ថាវត្ថុណាមួយពិតជាមាន ;

២– សេចក្ដីរីករាយត្រជាក់ចិត្ត ចំពោះគុណសម្បត្តិទាំងឡាយ ;

៣– សេចក្ដីប្រាថ្នា ឬបំណងចង់ឲ្យមានសមត្ថភាព អាចនឹងធ្វើឲ្យកើតនូវវត្ថុដែលរំពឹងឃើញ ។

ពុទ្ធសាសនិកត្រូវតែគេចវៀស ពីអំពើដែលប្រព្រឹត្តដោយកាយក៏ដូចជាដោយចិត្ត កុំឲ្យមានគំនិតប្រកាន់បក្សពួក ដែលជាទំនាស់នឹងសេចក្ដីសន្ដោសនិងសេរីភាព ។ អាស្រ័យហេតុនេះទោះបីមតិរបស់អ្នកដទៃយ៉ាងណាក៏ដោយ ពុទ្ធសាសនិកត្រូវតែគោរពដូចគ្នា កុំឲ្យតែមតិនោះប៉ះពាល់ដល់សុភមង្គលរបស់អ្នកដទៃ ។

យើងបានឃើញពីខាងលើមកថា ព្រះសម្ពុទ្ធទ្រង់យកជាប្រមាណតែចតុរារិយសច្ចប៉ុណ្ណោះ ។ អ្វីដទៃក្រៅដែលឥតទាក់ទងនឹងអរិយសច្ច ទ្រង់ពុំបានយកព្រះហឫទ័យទុកដាក់ហើយឧទាហរណ៍ដូចមាននៅក្នុងសូត្រឈ្មោះ **ចូឡមាលុង្ក្យវាទ** ក្នុងគម្ពីរមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ អះអាងបន្ថែមដូចតទៅ ៖

– សាវ័ករបស់ព្រះអង្គមួយរូបនាម **មាលុង្ក្យបុត្រ** ដែលនៅមានសង្ស័យក្នុងព្រះពុទ្ធសាសនាបានក្រាបបង្គំទូលសួរព្រះសាស្ដាថា ៖

– បពិត្រព្រះបរមគ្រូជាម្ចាស់ ពិភពលោកជានិច្ច ឬអនិច្ច ជាអន្ត ឬអនន្ត អាត្ម័ន ជាវត្ថុតែមួយជាប់នឹងកាយ ឬក៏ជាវត្ថុដោយឡែកដាច់ពីកាយ, ព្រះតថាគតនៅមានក្រោយពីមរណៈ ឬមានហើយ ។ នឹងមិនមានទេ ក្នុងកាលជាខាងក្រោយមរណៈ ? សាវ័កអង្គនេះបន្ថែមសេចក្ដីថា បើព្រះអង្គពុំអាចវិសជ្ជនា នឹងសំនួរទាំងនេះបានទេ សូមតបឲ្យច្បាស់ថា តថាគតមិនជ្រាប មិនឃើញទេ ដូច្នេះខ្ញុំព្រះអង្គនឹងអាលលាចាកសិក្ខាបទ ហើយចេញចាកទីនេះទៅរកកន្លែងដទៃ ។

ព្រះបរមគ្រូទ្រង់ត្រាស់សួរតបវិញថា :

— ម្នាលមាលុង្ក្យបុត្រ, តថាគតដែលប្រាប់អ្នកថា ចូរអ្នកមកបួសក្នុងសំណាក់តថាគត តថាគតនឹងពន្យល់អ្នកពីសំនួរទាំងនេះដែរឬទេ ?

— បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គពុំដែលឮមានព្រះពុទ្ធដីកាដូច្នេះទេ ។

— បើដូច្នេះមានតែអ្នកថា ខ្ញុំព្រះអង្គចូលមកកាន់ផ្នួសក្នុងសំណាក់របស់ព្រះអង្គ ដោយសារតែតថាគតនឹងពន្យល់ពីពាក្យសួរនេះឬ ?

— ខ្ញុំព្រះអង្គពុំបានទូលថ្វាយដូច្នេះទេ

— ឥឡូវនេះ លក្ខណ៍ទាំងពីរប្រការនេះ កើតឡើងទៅវិញទៅមកឬទេ ?

— សូមទ្រង់ព្រះមេត្តាប្រោស, ឥតមានទេ ។

— បើយ៉ាងនេះ ខ្លួនអ្នកដែលជាមនុស្សល្ងង់ខ្លៅនោះ ត្រូវដឹងថានរណាក៏ឥតទំលាក់កំហុសទៅវិញទៅមកដែរ គឺថាយើងទាំងពីររូបសឹងដល់នូវសេរីភាព ឥតមានភាតព្វកិច្ចនឹងបំពេញទៅវិញទៅមកឡើយ ។

មានត ...

## ពុទ្ធភាសិត

ខ្លួនទើបជាទីពឹងរបស់ខ្លួន ឯអ្នកដទៃដូចម្ដេចឡើយនឹងជាទីពឹងរបស់ខ្លួនបាន ព្រោះអ្នកដែលមានខ្លួនទូន្មានល្អហើយ រមែងបាននូវទីពឹងដែលគេរកបានដោយកម្រ។

ធម្មបទដ្ឋកថា អត្តវគ្គ

# កម្មវិធី

## នៃព្រះរាជពិធីបុណ្យឆ្លង និងបញ្ចុះខណ្ឌសីមាវត្ត
## ជោតញ្ញាណ គណៈមហានិកាយ និងវត្តឥន្ទញ្ញាណ គណៈធម្មយុត្តិកនិកាយ
## ក្រុងព្រះសីហនុ

## ពិធីបុណ្យបញ្ចុះខណ្ឌសីមាវត្តជោតញ្ញាណគណៈមហានិកាយ

ថ្ងៃទី ១ : *ថ្ងៃសុក្រ ៦ កើត ខែមិគសិរ ឆ្នាំមមី ត្រូវនឹងថ្ងៃទី ១៨ ខែវិច្ឆិកា ១៩៦៦*

### ពេលរសៀល :

ម៉ោង ១៦ – ០០ : – *អស់លោកមន្ត្រី ពុទ្ធបរិស័ទជួបជុំគ្នាក្នុងវត្តជោតញ្ញាណដើម្បីផ្តើមចូលពិធីបុណ្យ*

ម៉ោង ១៧ – ៣០ : – *អាចារ្យប្រកាសទេវតា ដោយមានភ្លេងពិណពាទ្យបន្ទីសូរស័ព្ទផង តាមប្រពៃ-ណីនៃព្រះរាជពិធី "ព្រោះវត្តនេះទើបកសាងថ្មី"*

ម៉ោង ១៨ – ០០ : – *ប្រគេនភេសជ្ជៈដល់ព្រះភិក្ខុសង្ឃ*

ម៉ោង ១៨ – ៣០ : – *ហែនិមិត្តសីមាចូលទៅតម្កល់ក្នុងព្រះវិហារ*

ម៉ោង ១៩ – ០០ : – *ព្រះភិក្ខុសង្ឃចំរើនព្រះបរិត្ត*

ម៉ោង ២០ – ៣០ : – *ទេសនាព្រះធម្មគោរព និងប្រឋមត្រាស់*

ម៉ោង ២២ – ០០ : – *ពិធីពុទ្ធាភិសេក*

– *ការកំសាន្តតាមសមគួរដល់កាល ។*

ថ្ងៃទី ២ : *ថ្ងៃសៅរ៍ ៧ កើត ខែមិគសិរ ឆ្នាំមមី ត្រូវនឹងថ្ងៃទី ១៩ ខែវិច្ឆិកា ១៩៦៦*

### ពេលព្រឹក :

ម៉ោង ៧ – ០០ : – *ប្រគេនយាគូដល់ព្រះសង្ឃ នៅទីដ៏គួរតាមការរៀបចំនៃពុទ្ធបរិស័ទទាំងពួង*

ម៉ោង ១០ – ៣០ : – *ប្រគេនចង្ហាន់ត្រង់ ដល់ព្រះភិក្ខុសង្ឃ នៅទីដ៏គួរដូចពេលព្រឹកដែរ*

### ពេលរសៀលទៅយប់ :

ម៉ោង ១៤ – ០០ : – *និមន្តធម្មកថិក ១ អង្គទេសនា បើពុទ្ធបរិស័ទត្រូវការឲ្យមាន*

ម៉ោង ១៥ – ៣០ : – *ព្រះភិក្ខុសង្ឃ ៣០ អង្គ និងពុទ្ធបរិស័ទជួបជុំគ្នាក្នុងវត្ត*

ម៉ោង ១៦ – ០០ : – *អស់លោកអ្នករាជការ អញ្ជើញដល់*

ម៉ោង ១៧ – ០០ : – *សម្តេចព្រះសង្ឃរាជថ្នាក់ទី ១ ស្តេចយាងដល់*

ម៉ោង ១៧ – ៣០ : – សម្ដេចព្រះប្រមុខរដ្ឋ ស្ដេចយាងដល់វត្ត

– ពួកពុទ្ធបរិស័ទថ្វាយសេចក្ដីគោរព

– សម្ដេចព្រះប្រមុខរដ្ឋ ស្ដេចយាងចូលក្នុងព្រះវិហារតាមទ្វារខាងមុខ

– ព្រះភិក្ខុសង្ឃថ្វាយជយន្តោ

– នមស្ការព្រះរតនត្រ័យ

– សូមសីល ៥

– សម្ដេចព្រះសង្ឃរាជថ្នាក់ទី ១ ថ្វាយសីល ៥

– វេរទីដីវត្តទាំងមូល រួចវេរព្រះវិហារ ព្រមទាំងកុដិ ២ ខ្នង រួចវេរដុំថ្មជានិមិត្តសីមា

– សម្ដេចព្រះប្រមុខរដ្ឋទ្រង់ប្រួចសុគន្ធវារី - ទក្សិណោទក លើបាទព្រះហស្ដស្ដាំនៃសម្ដេចព្រះសង្ឃរាជគណៈមហានិកាយ តាមសាសនៈប្រពៃណីជានិមិត្តរូបនៃការវេរវត្តអារាម និងសេនាសនៈក្នុងវត្ត ។

– សម្ដេចព្រះសង្ឃរាជថ្នាក់ទី ១ ប្រគល់ត្រា និងសញ្ញាប័ត្រសម្រាប់ចៅអធិការវត្ត

– ព្រះសង្ឃ ៣០ អង្គ បំរើនព្រះបរិត្ត ។

– សម្ដេចព្រះសង្ឃរាជថ្នាក់ទី ១ ថ្វាយគេនិយគាថា - យថា - អតិរេក ហើយថ្វាយព្រះរាជកុសល

– សម្ដេចព្រះប្រមុខរដ្ឋទ្រង់ប្រាស្រ័យគប

– សម្ដេចព្រះប្រមុខរដ្ឋទ្រង់ស្ដេចនិវត្ត

ម៉ោង ១៩ – ០០ : – ប្រគេនភេសជ្ជៈចំពោះព្រះភិក្ខុសង្ឃ

ម៉ោង ២០ – ៣០ : – ព្រះភិក្ខុសង្ឃ ៣០ អង្គចំរើនព្រះបរិត្ត

ម៉ោង ២១ – ៣០ : – ព្រះភិក្ខុសង្ឃច្រើនអង្គ មិនមានកំណត់ចំនួនជួបជុំក្នុងព្រះវិហារ ធ្វើពិធីសីមាសង្ឃកម្ម តាមលំអានព្រះវិន័យ ។

ថ្ងៃទី ៣ : ថ្ងៃអាទិត្យ ៨ កើត ខែមិគសិរ ឆ្នាំមមី ត្រូវនឹងថ្ងៃទី ២០ ខែវិច្ឆិកា ១៩៦៦

## ពេលព្រឹក :

ម៉ោង ៧ – ០០ : ប្រគេនយាគូចំពោះព្រះសង្ឃ

ម៉ោង ៨ – ០០ : – ពួកពុទ្ធបរិស័ទជួបជុំគ្នាគង់វត្ត

ម៉ោង ៨ – ៣០ : – សម្តេចព្រះសង្ឃរាជថ្នាក់ទី ១ ស្តេចយាងដល់

ម៉ោង ៩ – ០០ : – សម្តេចព្រះប្រមុខរដ្ឋ ស្តេចយាងដល់

– នារី ៣ នាក់ថ្វាយបាច់ផ្កា

– ពុទ្ធបរិស័ទថ្វាយសេចក្តីគោរព

– ក្រុមទាហានធ្វើការវគិច្ចថ្វាយ

– ស្តេចយាងឡើងគង់ប្រថាប់លើវេទិកាកិត្តិយស

– ចម្រៀងថ្វាយព្រះពរ

– បទនីគេងជាតិថ្វាយ

– ព្រះភិក្ខុសង្ឃថ្វាយជយន្តោ

– សុន្ទរកថា ថ្លែងដោយចៅហ្វាយក្រុង

– ព្រះសង្ឃថាសម្តេចព្រះសង្ឃរាជ

– ព្រះសង្ឃថាសម្តេចព្រះប្រមុខរដ្ឋ

– សម្តេចព្រះប្រមុខរដ្ឋ ស្តេចយាងចូលព្រះវិហារតាមទ្វារខាងមុខ

– សម្តេចព្រះប្រមុខរដ្ឋ ទ្រង់ប្រោះព្រះគ្គការកាត់ប្ញសសីមា

– ភ្លេងតន្ត្រីបទនីស្សរស័ព្ទអឹងកងឡើង

– ព្រះភិក្ខុសង្ឃសូត្រធ្យាយធម៌មង្គលសូត្រឆ្លងបុណ្យ

– សម្តេចព្រះប្រមុខរដ្ឋទ្រង់ប្រគេនទេយ្យទានចំពោះព្រះភិក្ខុសង្ឃ

– សម្តេចព្រះសង្ឃរាជថ្នាក់ទី ១ ថ្វាយគេនិយគាថា - យថា - អតិរេក រួចថ្វាយព្រះប្រសិទ្ធិពរជ័យ សិរីសុភមង្គល វិបុលសុខគ្រប់ប្រការ ចំពោះសម្តេចព្រះប្រមុខរដ្ឋ ព្រមទាំងប្រកាសសាធុការពរចំពោះអស់លោក-អ្នករាជការនិងពុទ្ធបរិស័ទទូទៅ ក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល

– សម្តេចព្រះប្រមុខរដ្ឋស្តេចនិវត្ត ។

ម៉ោង ១០ – ៣០ : – ប្រគេនចង្ហាន់ត្រង់ចំពោះព្រះភិក្ខុសង្ឃ

### ពេលល្ងាច :

ម៉ោ ១៤ – ០០ : – ពុទ្ធបរិស័ទជួបជុំនៅក្នុងវត្ត

– ទេសនាសង្គាយនាឆ្លងបុណ្យ

ចប់ពិធីបុណ្យបញ្ចុះខណ្ឌសីមាខាងគណៈមហានិកាយ

---

## ពិធីបុណ្យបញ្ចុះខណ្ឌសីមាវត្តឥន្ទញ្ញាណគណៈធម្មយុត្តិកនិកាយ

ថ្ងៃទី ៣ : ថ្ងៃអាទិត្យ ៨ កើត ខែមិគសិរ ឆ្នាំមមី ត្រូវនឹងថ្ងៃទី ២០ ខែវិច្ឆិកា ១៩៦៦

### ពេលរសៀល :

ម៉ោង ១៦–០០ : – អស់លោកមន្ត្រី ពុទ្ធបរិស័ទជួបជុំគ្នាក្នុងវត្តឥន្ទញាណ ដើម្បីផ្ដើមចូលពិធីបុណ្យ

ម៉ោង ១៧–៣០ : – អាចារ្យប្រកាសទេវតា ដោយមានភ្លេងពិណពាទ្យបន្ទំស័ព្ទផង តាមប្រពៃណីនៃព្រះរាជពិធី " ព្រោះវត្តនេះទើបកសាងថ្មី "

ម៉ោង ១៨–០០ : – ប្រគេនភេសជ្ជៈដល់ព្រះភិក្ខុសង្ឃ

ម៉ោង ១៨–៣០ : – ហែនិមិត្តសីមាចូលទៅតំកល់ក្នុងព្រះវិហារ

ម៉ោង ១៩–០០ : – ព្រះភិក្ខុសង្ឃចំរើនព្រះបរិត្ត

ម៉ោង ២០–៣០ : – ទេសនាព្រះធម្មគោរព និងប្រថមត្រាស់

ម៉ោង ២២–០០ : – ពិធីពុទ្ធាភិសេក

– ការកំសាន្តតាមសមគួរដល់កាល ។

ថ្ងៃទី ៤ : ថ្ងៃចន្ទ ៩ កើត ខែមិគសិរ ឆ្នាំមមី ត្រូវនឹងថ្ងៃទី ២១ ខែវិច្ឆិកា ១៩៦៦

### ពេលព្រឹក :

ម៉ោង ៧–០០ : – ប្រគេនយាគូដល់ព្រះសង្ឃ នៅទីដ៏គួរតាមការលៃលកនៃពុទ្ធបរិស័ទទាំងពួង

ម៉ោង ១០–៣០ : – ប្រគេនចង្ហាន់ត្រង់ ដល់ព្រះភិក្ខុសង្ឃនៅទីដ៏គួរដូចពេលព្រឹកដែរ

### ពេលរសៀល ទៅយប់

ម៉ោង ១៤–០០ : – និមន្តធម្មកថិក ១ អង្គទេសនា បើពុទ្ធបរិស័ទត្រូវការឲ្យមាន

ម៉ោង ១៥–៣០ : – ព្រះភិក្ខុសង្ឃ ៣០ អង្គ និងពុទ្ធបរិស័ទជួបជុំគ្នាក្នុងវត្ត

ម៉ោង ១៦–០០ : – អស់លោកអ្នករាជការ អញ្ជើញដល់វត្ត

ម៉ោង ១៧–០០ : – សម្ដេចព្រះសង្ឃនាយកនិមន្តដល់

ម៉ោង ១៧–៣០ : – សម្ដេចព្រះប្រមុខរដ្ឋ ស្ដេចយាងដល់វត្ត

– ពួកពុទ្ធបរិស័ទថ្វាយសេចក្ដីគោរព

– សម្ដេចព្រះប្រមុខរដ្ឋ ស្ដេចយាងចូលក្នុងព្រះវិហារតាមទ្វារខាងមុខ

– ព្រះភិក្ខុសង្ឃថ្វាយជយន្តោ

– នមស្ការព្រះរតនត្រ័យ

– សូមសីល ៥

– សម្ដេចព្រះសង្ឃនាយកថ្វាយសីល ៥

– វេរទីដីវត្តទាំងមូល រួចវេរព្រះវិហារ ព្រមទាំងកុដិ ២ ខ្នង រួចវេរដុំថ្មជានិមិត្តសីមា

– សម្ដេចព្រះប្រមុខរដ្ឋទ្រង់ប្រួចសុគន្ធវារី - ទក្សិណោទក លើបាទព្រះហស្ដស្ដាំនៃ សម្ដេចព្រះសង្ឃនាយកតាមសាសនៈប្រពៃណី ជានិមិត្តរូបនៃការវេរវត្តអារាម និងសេនាសនៈក្នុងវត្ត ។

– សម្ដេចព្រះសង្ឃនាយកប្រគល់ត្រានិងសញ្ញាប័ត្រសម្រាប់ចៅអធិការវត្ត

– ព្រះសង្ឃ ៣០ អង្គចំរើនព្រះបរិត្ត

– សម្ដេចព្រះសង្ឃនាយកថ្វាយកេនិយគាថា - យថាអតិរេក ហើយផ្សាយព្រះរាជ-កុសល

– សម្ដេចព្រះប្រមុខរដ្ឋទ្រង់ប្រោស្រ័យតប

– សម្ដេចព្រះប្រមុខរដ្ឋស្ដេចនិវត្ត

ម៉ោង ១៩–០០ : – ប្រគេនភេសជ្ជៈដល់ព្រះភិក្ខុសង្ឃ

ម៉ោង ២០–៣០ : – ព្រះភិក្ខុសង្ឃ ៣០ អង្គចំរើនព្រះបរិត្ត

ម៉ោង ២១–៣០ : – ព្រះភិក្ខុសង្ឃច្រើនអង្គ មិនមានកំណត់ចំនួនជួបជុំក្នុងព្រះវិហារ ធ្វើពិធីសីមាសង្ឃកម្មតាមលំអានព្រះវិន័យ ។

ថ្ងៃទី ៥ : ថ្ងៃអង្គារ ១០ កើត ខែមិគសិរ ឆ្នាំមមី ត្រូវនឹងថ្ងៃទី ២២ ខែវិច្ឆិកា ១៩៦៦

## ពេលព្រឹក :

ម៉ោង ៧–០០ : – ប្រគេនយាគូដល់ព្រះសង្ឃ

ម៉ោង ៨–០០ : – ពុកពុទ្ធបរិស័ទជួបជុំគ្នាក្នុងវត្ត

ម៉ោង ៨–៣០ : – សម្ដេចព្រះសង្ឃនាយកនិមន្តដល់

ម៉ោង ៩–០០ : – សម្ដេចព្រះប្រមុខរដ្ឋ ស្ដេចយាងដល់វត្ត

– នារី ៣ នាក់ថ្វាយបាច់ផ្កា

– ពុទ្ធបរិស័ទថ្វាយសេចក្ដីគោរព

– ក្រុមមហោស្រពធ្វើការកិច្ចថ្វាយ

– ស្ដេចយាងឡើងគង់ប្រថាប់លើវេទិកាកិត្តិយស

– ចម្រៀងថ្វាយព្រះពរ

– បន្ទឹភ្លេងជាតិថ្វាយ

– ព្រះភិក្ខុសង្ឃថ្វាយជយន្ដោ

– សុន្ទរកថា ថ្លែងដោយចៅហ្វាយក្រុង

– ព្រះសង្ឃថាសម្ដេចព្រះសង្ឃនាយក

– ព្រះសង្ឃថាសម្ដេចព្រះប្រមុខរដ្ឋ

– សម្ដេចព្រះប្រមុខរដ្ឋ ស្ដេចយាងចូលក្នុងព្រះវិហារតាមទ្វារខាងមុខ

– សម្ដេចព្រះប្រមុខរដ្ឋ ទ្រង់ប្រោះព្រួសការកាត់ឫសសីមា

– ភ្លេងតន្ត្រីបន្ទឹស័ព្ទអឹងកង់ឡើង

– ព្រះភិក្ខុសង្ឃស្វាធ្យាយធម៌មង្គលសូត្រឆ្លងបុណ្យ

– សម្ដេចព្រះប្រមុខរដ្ឋ ទ្រង់ប្រគេនទេយ្យទានដល់ព្រះភិក្ខុសង្ឃ

– សម្ដេចព្រះសង្ឃនាយក ថ្វាយគេនិយគាថា • យថាអតិរេក រួចថ្វាយព្រះសិទ្ធិពរជ័យសិរីសុភមង្គល វិបុលសុខគ្រប់ប្រការចំពោះសម្ដេចព្រះប្រមុខរដ្ឋ ព្រមទាំងប្រកាសសាធុការពរចំពោះអស់លោកអ្នករាជការនិងពុទ្ធបរិស័ទទូទៅក្នុងព្រះរាជា-

ណាចក្រកម្ពុជាទាំងមូលផង

— សម្ដេចព្រះប្រមុខរដ្ឋ ស្ដេចនិវត្ត

ម៉ោង ១១–៣០ : – ប្រគេនចង្ហាន់ត្រង់ដល់ព្រះភិក្ខុសង្ឃ

## ពេលល្ងាច :

ម៉ោង ១៤–០០ : – ពុទ្ធបរិស័ទជួបជុំនៅវត្ត

– ទេសនាសង្គាយនាធុងបុណ្យ

ចប់ពិធីបុណ្យបញ្ចុះខណ្ឌសីមាខាងគណៈធម្មយុត្តិកនិកាយ ។

---

## ពុទ្ធភាសិត

បើបានជាជ្រួលធ្វើបាបម្ដងហើយ ត្រូវកុំធ្វើបាបនោះឲ្យរឿយៗ តទៅទៀត ត្រូវកុំធ្វើសេចក្ដីពេញចិត្តចំពោះបាបនោះឲ្យសោះ ព្រោះការសន្សំបាប រមែងនាំទុក្ខមកឲ្យដល់ខ្លួនអ្នកធ្វើវិញពុំខានឡើយ ។

ធម្មបទដ្ឋកថា បាបវគ្គ

# ចរប្បសិទ្ធិគាថា

" គាថាប្រសិទ្ធិពរ "

*សម្រាប់សូត្រកន្សែងជោគញាណ*

ក្រុងព្រះសីហនុ

តែងដោយ


សម្ដេចព្រះមហាសុមេធាធិបតី

ជ. ណ. ជោតញ្ញាណោ

ព្រះសង្ឃរាជថ្នាក់ទី ១

នៃគណៈមហានិកាយ


ព. ស. ២៥០៦ គ. ស. ១៩៦៤

# ជរប្បសិទ្ធិគាថា

« គាថាប្រសិទ្ធិពរ »

សម្រាប់សូត្រក្នុងចត្តុរជោតញ្ញាណ

ក្រុងព្រះសីហនុ

យោ ហិ ពុទ្ធញ្ច ធម្មញ្ច សង្ឃញ្ច រតនត្តយំ
បសន្នោ សរណំ គតោ សោ វេ ធុត្វា បមុញ្ចរេ ។
សីហនុនគរេ អស្មឹ បព្វតេសុ វនេសុ វា
សមុទ្ទេ ខុទ្ទកេ ទីបេ រុក្ខេសុ វា ឋិតា មរូ
យក្ខា ភូតា បិសាចា ច អសុរា ទករក្ខសា
អប្បេសក្ខា មហេសក្ខា យេ ចរញ្ញទិស្សមានកា
ពុទ្ធំ ធម្មញ្ច សង្ឃញ្ច គច្ឆន្តុ សរណំ សទា
ពុទ្ធធម្មេ បសីទន្តុ រក្ខន្តុ ពុទ្ធសាសនំ
បុញ្ញំ នោ អនុមោទន្តុ និច្ចំ បាលេន្តុ នោ សទា
តទានុមោទនាយេវ សោត្ថី លភន្តុ ទេវតា ។

អម្ហាកំ រដ្ឋប្បមុខោ សីហនុឥតិនាមកោ
ធម្មេន រដ្ឋំ បាលេន្តោ រាជធម្មេ ឋិតោ សទា
សព្វេ តញ្ញាភិបាលេន្តុ ជយត្ថាយ សុខាយ ច
សីហនុ សោ មហាតេជោ ទីឃាយុកោ មហិទ្ធិកោ
ពលានុភាវសម្បន្នោ ជយវា ហោតុ សព្វទា
យញ្ច បទេសំ គច្ឆន្តោ យសវា តត្ថ តេជសី
យា តេនុទីរិតា វាចា សារវន្តី សុភាសិតា
បិយា ហោតុ មនាបា ច បរទេសាធិវាសិនំ ។

សព្វេ ករម្មាជិកា ហោន្តុ អនលសា ច វីរិយា
ឯកច្ឆន្ទា សមគ្គា ច សម្បត្តិបរិបូរកា
សីលធម្មេ ឋិតា ហោន្តុ ពុទ្ធធម្មេ សគារវា
កតញ្ញុនោ សទា ហោន្តុ បូរេន្តុ កតវេទិតំ ។

ឥទំ កម្មជវឌ្ឍន្តុ　　សន្តិភាវេ ឋិតំ សទា
អព្យាភតេភរវេ្ទ　　តិដ្ឋតុ វា និរន្តរំ
យេ យេ ឥមស្សមិត្តា ចេ　　តេ តេ មិត្តា សហាយកា
សមចិត្តា ច ធម្មេន　　សមេន ហោន្តុ សព្វទា
មេត្តាការុញ្ញចិត្តា ច　　មុទិតូបេក្ខកា សទា
មិត្តភាវេ ឋិតា ហោន្តុ　　អញ្ញមញ្ញានុកម្បកា ។

រតនត្តយតេជេន　　កាលេ ទេវោ បវស្សតុ
កសិកម្មាទិកម្មេហិ　　អភិវឌ្ឍន្តុ កស្សកា
តទញ្ញេ វាណិជា យេ វា　　កម្មការាបិ តេ ជនា
ធម្មដ្ឋា សីលសម្បន្នា　　សុខិតា ហោន្តុ សព្វទា
យំ យម្បិចាតិបជ្ជន្តិ　　តំ តំ ខិប្បំ សមិជ្ឈតុ
វុឌ្ឍី វិរុឡ្ហី បប្បោន្តុ　　សន្តិភាវញ្ច នាញ្ញថា ។

បុព្វេ ឥធ វិហារោ វា　　សង្ឃារាមោ ន ទិស្សរេ
វិហារោ នវការាវាសោ　　អធុនាយេវ ទិស្សតេ ។
ជោតញ្ញាណោ វិហារោយំ　　សហ សេនាសនេហិ ច
សីហានុនា បមុខេន　　ការាបិតោ វ សព្វសោ
សង្ឃស្សានុប្បទាបេសិ　　ពុទ្ធវស្សេ ធនូមរេ
បដិគ្គហេសិមំ សង្ឃោ　　សោមនស្សេន ចេតសា ។

យេ យេ វា នវកា ថេរា　　ឥមស្មឹ អធិវាសិនោ
តេ តេ ទេវាភិបាលេន្តុ　　សុខិតា ហោន្តុ តេ សទា ។
តីហិ សិក្ខាហិ វឌ្ឍន្តុ　　និទ្ទុក្ខា និរុបទ្ទវា
អព្យាបជ្ឈា អវេរី ច　　ទីឃាយុកា ច ហោន្តុ តេ ។
យានិ សិក្ខាបទានេវ　　បញ្ញត្តានិ មហេសិនា
សក្កច្ចំ អនុវត្តន្តុ　　មា ហោន្តុ សប្បមាទិនោ ។
អបរិហានិយា ធម្មា　　សម្ពុទ្ធេនប្បកាសិតា
តេសុ ច បដិបជ្ជន្តុ　　វុឌ្ឍិយា ពុទ្ធសាសនេ ។

ខមា ជាគរិយុដ្ឋានំ　　សំវិភាគោ ទយិក្ខណា
នាយកស្ស គុណា ឯតេ　　ឥច្ឆិតព្វា សតំ គុណា ។
ឆយិមេ នាយកា ធម្មា　　ភគវតា ច ទេសិតា
ឥមេសុ បដិបជ្ជន្តុ　　មា ជហន្តុ បមាទតោ ។
យស្មឹ ហិ ឆយិមេ ធម្មា　　សព្វកាលេ បតិដ្ឋិតា
តស្មឹ វុឌ្ឍី វិរុឡ្ហី ច　　ឧប្បជ្ជន្តិ អនញ្ញថា ។

សព្វរោគវិនីមុត្តា　　សព្វសន្តាបវជ្ជិតា
សព្វវេរមតិក្កន្តា　　និទ្ទុក្ខា ហោន្តុ សាធវោ !

ជោតញ្ញាណោនិមា គាថា
សង្ឃរាជេន ធីមតា
រចិតា សាវនត្ថាយ
ពុទ្ធសកេ ធន្វមរេ ។

ជ. ណ.

# ប្រែសម្រួលសេចក្ដី

## ពីបាលីទាំង ២៨ គាថា

### ប្រសិទ្ធិពរ សម្រាប់សូត្រក្នុងវត្តជោតញ្ញាណ

### ក្រុងព្រះសីហនុ

"តាមការណ៍ពិតថា បុគ្គលណាមានចិត្តជ្រះថ្លា បានដល់នូវព្រះរត្នត្រ័យ គឺ **ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ** ជា **សរណៈ** ហើយ បុគ្គលនោះតែងតែរួចស្រឡះចាកទុក្ខ ។ ទេវតា យក្ខ ភូត បិសាច អសុរ អារក្ខទឹក ទាំងឡាយណា មានសក្តានុភាពតូចក្តីធំក្តី ទាំងអទិស្សមានកាយទាំងឡាយណាដទៃក្តី ដែលឋិតនៅក្នុងក្រុងព្រះសីហនុនេះ គឺដែលឋិតនៅនាភ្នំ នាព្រៃ នាសមុទ្រ នាកោះតូច (ធំ) នាដើមឈើ ទាំងឡាយក្តី (អទិស្សមានកាយទាំងឡាយមានទេវតាជាដើមនោះ) ចូរដល់នូវ **ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ** ជា **សរណៈ** សព្វកាលវេលា, ចូរជ្រះថ្លាចំពោះធម៌នៃព្រះពុទ្ធ, ចូររក្សានូវព្រះពុទ្ធសាសនា, ចូរអនុមោទនាត្រេកអរចំពោះបុណ្យរបស់យើង, ចូរអភិបាលរក្សានូវយើង សព្វកាលវេលាជានិច្ច; ដោយការអនុមោទនាចំពោះបុណ្យរបស់យើងនោះ ទេវតាទាំងឡាយចូរបាននូវសុខសួស្តិចុះ!

**សម្តេចព្រះនរោត្តម សីហនុ ឧបយុវរាជ ព្រះប្រមុខរដ្ឋនៃយើង** ព្រះអង្គគ្រប់គ្រងរក្សានូវ **កម្ពុជរដ្ឋ** ដោយយុត្តិធម៌ ទ្រង់ឋិតនៅក្នុងរាជធម៌សព្វកាលវេលា, សូមអទិស្សមានកាយទាំងពួងមានទេវតាជាដើម អភិបាលរក្សានូវព្រះអង្គ ដើម្បីព្រះអង្គមានជ័យជំនះនិងសេចក្តីសុខ ! សូម **សម្តេចព្រះនរោត្តម សីហនុ** ព្រះអង្គនោះ ទ្រង់មានព្រះមហាតេជះ និងឫទ្ធីមហិមា មានព្រះជន្មវស្សាទីឃាយុយឺន បរិបូណ៌ដោយពលានុភាពមានជ័យជំនះ សព្វកាលវេលា! បើព្រះអង្គស្តេចយាងទៅកាន់ប្រទេសណា ៗ សូមព្រះអង្គមានយសបរិវារ មានព្រះតេជះ ក្នុងប្រទេសនោះ ៗ, ព្រះវាចាណាដែលព្រះអង្គបានថ្លែងហើយ សូមព្រះសុភាសិតាវាចាដ៏មានខ្លឹមសារ (នោះ) ជាទីស្រឡាញ់ពេញចិត្ត នៃជនានុជនអ្នកបរទេសទាំងឡាយ !

សូមឲ្យ **ប្រជាពលរដ្ឋ** អ្នកនៅក្នុងប្រទេសកម្ពុជាទាំងមូល មានឧស្សាហ៍ព្យាយាម កុំបីជាអ្នកខ្ជិលច្រអូសឡើយ, សូមឲ្យជាអ្នកមានសាមគ្គីនិងឆន្ទៈរួបរួមគ្នាជាធ្លុងមួយ, ជាអ្នកបំពេញកិច្ចការរបរឲ្យមានទ្រព្យសម្បត្តិសម្បូណ៌, ជាអ្នកឋិតនៅក្នុងសីលធម៌ ប្រកបដោយសេចក្តីគោរពចំពោះធម៌នៃព្រះពុទ្ធ, ជាអ្នកដឹងនូវឧបការៈនៃអ្នកមានគុណ, ចូរបំពេញនូវកតវេទិតាធម៌ គឺការតបឧបការៈនៃអ្នកមានគុណ សព្វកាលវេលា !

មួយទៀត, **រីកម្ពុជរដ្ឋនេះ** ចូរឋិតនៅក្នុង **សន្តិភាព** សព្វកាលវេលា, ទាំងឋិតនៅក្នុង **ឯករាជ្យ អព្យាក្រឹត** ជានិច្ចនិរន្តរ៍ផង ! ប្រសិនបើមានជនទាំងឡាយណា ៗ ជាបច្ចាមិត្រប្រទូស្តប្រទាំងប្រឆាំងចំពោះកម្ពុជរដ្ឋនេះ, ជនទាំងឡាយនោះៗ **ចូរប្រែក្លាយមកជាមិត្រ ប្រែក្លាយមកជាគ្នា, ចូរមានចិត្តស្មោះត្រង់** ដោយសុចរិតយុត្តិធម៌ដ៏ស្មើ ជានិច្ចកាល, ចូរមានចិត្តប្រកបដោយ **មេត្តា ករុណា មុទិតា ឧបេក្ខា,** ជាអ្នកឋិតនៅ **ក្នុងមិត្តភាព មានការយោគយល់គ្នាទៅវិញទៅមក** សព្វកាលវេលា !

ដោយតេជះនៃព្រះរត្នត្រ័យ, សូមវស្សវលាហកទេវតា បង្អុរនូវទឹកភ្លៀង ឲ្យបានត្រឹមត្រូវតាមរដូវកាលមក ! កសិករគឺអ្នកធ្វើស្រែចំការទាំងឡាយ ចូរចំរុងចំរើនដោយការរបរទាំងឡាយមានកសិកម្មជាដើម, ជនទាំងឡាយណាដទៃក្រៅពីពួកកសិករទាំងនោះ ទោះជាអ្នកជំនួញក្តី ជាកម្មករក្តី, ជនទាំងឡាយនោះ ចូរជាអ្នកឋិតនៅក្នុងសុចរិតយុត្តិធម៌បរិបូណ៌ដោយសីល ប្រកបដោយសេចក្តីសុខ រៀងរាល់វេលា ! បើជនទាំងនោះប្រាថ្នាចង់បាននូវវត្ថុណា ៗ សូមឲ្យវត្ថុនោះ ៗ សម្រេចរួសរាន់ទាន់ចិត្ត ! សូមឲ្យបានដល់នូវសន្តិភាព និងការលូតលាស់ចំរើន កុំបីប្រែក្លាយទៅជាហេតុការណ៍ដទៃក្រៅពីនោះឡើយ !

កាលពីដើម, លើទីភ្នំនេះ ឥតមានវត្តជាអារាមនៃព្រះភិក្ខុសង្ឃសោះទេ, លុះដល់មកក្នុងបច្ចុប្បន្នកាលនេះ ទើបមានវត្តជាអាវាសថ្មីប្រាកដឡើង ៗ **វត្តជោតញ្ញាណនេះ** ព្រមទាំងសេនាសនៈទាំងឡាយ កើតមានឡើងដោយ **សម្តេចព្រះនរោត្តម សីហនុ ព្រះប្រមុខរដ្ឋ** ព្រះអង្គមានព្រះរាជបញ្ជាឲ្យស្ថាបនា ដោយសព្វគ្រប់ ហើយព្រះអង្គបានវេរប្រគេនដល់ព្រះភិក្ខុសង្ឃ ក្នុងពុទ្ធសករាជ ២៥០៩ – ព្រះភិក្ខុសង្ឃក៏បានទទួលវត្តនេះ ដោយសោមនស្សចេតនា ៗ

បព្វជិតទាំងឡាយណា ៗ ជានវកភិក្ខុក្តី ជាថេរៈក្តី ដែលមកនៅអាស្រ័យក្នុង **វត្តជោតញ្ញាណនេះ,** សូមពពួកទេវតា អភិបាលរក្សានូវបព្វជិតទាំងឡាយនោះ ៗ , សូមឲ្យបព្វជិតទាំងនោះ ប្រកបដោយសេចក្តីសុខ សព្វកាលវេលា !

បព្វជិតទាំងឡាយនោះ ចូរចំរុងចំរើនដោយត្រៃសិក្ខាគឺ **សីល សមាធិ បញ្ញា !** សូមឲ្យនិរាសចាកទុក្ខ និរាសចាកឧបទ្រព កុំប្រណែនព្យាបាទផ្តួនាគ្នា កុំចងពៀរនឹងគ្នា សូមឲ្យមានអាយុវែងរាល់ប្រាណ !

សិក្ខាបទទាំងឡាយណា ដែលព្រះមហាសីសព្វញ្ញុពុទ្ធ ទ្រង់បញ្ញត្តហើយ, បព្វជិតទាំងឡាយ

ចូរអនុវត្ត គឺប្រព្រឹត្តប្រតិបត្តិតាម (សិក្ខាបទទាំងនោះ) ដោយគោរព, ចូរកុំបីមានសេចក្ដីប្រមាទ ប្រហែសធ្វេសពាយឆាយឡើយ !

ភិក្ខុអបរិហានិយធម៌ទាំងឡាយ (៧ ប្រការ) ដែលព្រះសម្ពុទ្ធទ្រង់សំដែងហើយ, បព្វជិតទាំងឡាយ ចូរប្រព្រឹត្តប្រតិបត្តិតាមអបរិហានិយធម៌ទាំងនោះ ដើម្បីសេចក្ដីចំរើនក្នុងព្រះពុទ្ធសាសនា !

នាយកធម៌ គឺបែបបទសម្រាប់អ្នកគ្រប់គ្រង (មាន ៦ ប្រការ) គឺ **ខមា** ការអត់ធន់ ១ **ជាគរិយៈ** ការភ្ញាក់រលឹកនឹកឃើញមិនភ្លាំងភ្លេច ១ **ឧដ្ឋានៈ** ការមានព្យាយាមរឹងប៉ឹងម៉ឺងម៉ាត់ ១ **សំវិភាគៈ** ការចែករលែក ឬការរំលែកចែកឲ្យ ១ **ទយា** ការអាណិតអាសូរគេ ១ **ឥក្ខណា** ការរំពៃមើលត្រួតត្រាមុខការរបស់ខ្លួន ១, នាយកធម៌ទាំង ៦ ប្រការនេះ ជាគុណធម៌ដែលសប្បុរសជនទាំងឡាយគប្បីត្រូវការ ៗ

នាយកធម៌ទាំង ៦ ប្រការនេះ ជាធម៌ដែលព្រះភគវតបរមគ្រូទ្រង់សំដែងហើយ, បព្វជិតទាំងឡាយ ចូរប្រតិបត្តិតាមលំអានធម៌ទាំងនេះ, ចូរកុំបោះបង់ចោលដោយការធ្វេសប្រហែសពាយឆាយឡើយ ។ មែនពិត, នាយកធម៌ទាំង ៦ នេះ ប្រតិស្ឋាននៅសព្វកាលវេលាក្នុងទីណា, ការលូតលាស់ចំរើន តែងតែកើតមានក្នុងទីនោះ ពុំប្រែក្លាយទៅជាហេតុការណ៍ដទៃក្រៅពីនោះឡើយ ។

សូមសាធុជនទាំងឡាយ

បានរួចផុតស្រឡះចាករោគាពាធទាំងពួង !

បានគេចផុតស្រឡះចាកសេចក្ដីក្ដៅក្រហាយទាំងពួង !

បានកន្លងបង់នូវពៀរទាំងពួង !

បាននិរាសចាកទុក្ខ (ជានិច្ចនិរន្តរ៍តរៀងទៅ) ! ។

ថ្ងៃ ៧ ៗ ៣ ៣ ឆ្នាំថោះបញ្ចស័ក ព. ស. ២៥០៦

ត្រូវនឹងថ្ងៃទី ១ កុម្ភៈ គ. ស. ១៩៦៤

**សម្ដេចព្រះមហាសុមេធាធិបតី**

**ជ. ណ. ជោតញ្ញាណោ**

**ព្រះសង្ឃរាជថ្នាក់ទី ១**

**នៃគណៈមហានិកាយ**

# ពិធីសម្ពោធឆ្លង – បញ្ចុះខណ្ឌសីមា

# វត្តជោតញ្ញាណ និង វត្តឥន្ទញ្ញាណ

ក្រុងព្រះសីហនុ

– សម្រាប់វត្តជោតញ្ញាណ គណៈមហានិកាយ ពីថ្ងៃសុក្រ ១៨ វិច្ឆិកា ដល់ថ្ងៃអាទិត្យទី ២០ វិច្ឆិកា ១៩៦៦

– សម្រាប់វត្តឥន្ទញ្ញាណ គណៈធម្មយុត្តិកនិកាយ ពីថ្ងៃអាទិត្យ ២០ វិច្ឆិកា ដល់ថ្ងៃអង្គារទី ២២ វិច្ឆិកា ១៩៦៦

# ពេជនិកល្អទះព្រោម – ខុស្ថាក្រឡរមនិពី

## លោកញ្ញាអ្នកក្ដូច និង លោកញ្ញាកាវៈក្ដូច

នុកាយមិនះញៀមខត្ស

ក្បួនៃ ៦០ ក្បុក្រហ្វ៊ូក៏ យគេនិក្រាមៈណាគ លោកញ្ញាគាវៈក្ដូប៉េមៀរកា –
៤៨៦០ ក្បួនៃ ០៧ ទិក្រទីអេង្វ៊ូហ៊ាង

គេប្ហីនៃ ០៧ ក្រូទិអេង្វ៊ូក៏ យគេនិកក្តីយមួរៈណាន លោកញ្ញាខ្នកក្ដូប៉េមៀរកា –
៤៨៦០ គេប្ហីនៃ ៧៧ ទិអេង្អូអង្វ៊ូហ៊ាង



**ព្រះបាទសម្តេចព្រះនរោត្តម - សីហនុវរ្ម័ន សង្គមរាស្ត្រនិយម**

ទ្រង់ប្រសូតនៅថ្ងៃ ១១ កើត ខែកត្តិក ឆ្នាំចចត្វាស័ក ត្រូវនឹងថ្ងៃទី ៣១ តុលា គ. ស. ១៩២២, ទ្រង់ឡើងសោយរាជ្យ នៅថ្ងៃពុធ ១២ រោច ខែចេត្រ ឆ្នាំម្សាញ់ត្រីស័ក ត្រូវនឹងថ្ងៃទី ២៣ មេសា គ. ស. ១៩៤១, ទ្រង់ដាក់រាជសម្បត្តិ នៅថ្ងៃព្រហស្បតិ៍ ១០ កើត ខែផល្គុណ ឆ្នាំមមីឆស័ក ត្រូវនឹងថ្ងៃទី ៣ មីនា គ. ស. ១៩៥៥

# ប្រវត្តិវត្តនៅក្រុងព្រះសីហនុ

បន្ទាប់ពីមានការស្ថាបនាក្រុងព្រះសីហនុ ក្នុង គ.ស. ១៩៥៥ នៅកំពង់សោម ជាអតីតដែនដីរបស់ខេត្តកំពត តាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់នៃសម្តេចសហជីវិនព្រះប្រមុខរដ្ឋនោះមក, ពលរដ្ឋនៃក្រុងនេះ ដែលទើបនឹងទៅតាំងលំនៅជាថ្មី បាននាំគ្នាសុំបង្កើតវត្តមួយជាបណ្តោះអាសន្ន ហៅថា **វត្តគិរីគង្គា** ដែលតាំងនៅខាងក្រោយផ្សារចាស់ ប៉ុន្តែក្នុង គ.ស. ១៩៥៨ ដោយរាជការក្រុងបានតម្រូវរៀបចំកន្លែងនោះធ្វើជាសួនច្បារ, វត្តនេះ ក៏ត្រូវរុះរើទៅតាំងនៅភូមិនេសាទរហូតដល់សព្វថ្ងៃនេះ ។ កុដិ និងព្រះវិហារនៃវត្តនេះធ្វើអំពីឈើមូល ជញ្ជាំងសំបកឈើគគីរខ្ទប់ ដំបូលប្រក់ស្លឹក ។

ក្នុងខែកុម្ភៈ ១៩៦២ សម្តេច **ព្រះនរោត្តម - សីហនុ** ព្រះប្រមុខរដ្ឋ នៃប្រទេសកម្ពុជា បានទ្រង់ដឹកនាំពលរដ្ឋគ្រប់ក្រុង, គ្រប់ខេត្ត ក្នុងព្រះរាជាណាចក្រទាំងមូលឲ្យប្រជុំគ្នាធ្វើបុណ្យផ្កាមួយដង្ហែចូលក្រុង **ព្រះសីហនុ** ដើម្បីទ្រង់ស្ថាបនាវត្តពីរគឺ វត្តគណៈមហានិកាយមួយ និងវត្តគណៈធម្មយុត្តិកនិកាយមួយ ។

ចំពោះវត្តគណៈមហានិកាយ សម្តេចសហជីវិនព្រះប្រមុខរដ្ឋ ទ្រង់បានព្រះរាជទាននាមថា **វត្តជោតញ្ញាណ** ដោយយកព្រះបព្វជិតនាមនៃសម្តេចព្រះមហាសុមេធាធិបតី ព្រះនាមដើម **ជួន - ណាត** ជាព្រះសង្ឃរាជថ្នាក់ទី ១ នៃគណៈមហានិកាយ ឲ្យជានាមនៃវត្តនេះ ។

ចំណែកវត្តគណៈធម្មយុត្តិកនិកាយ ព្រះអង្គទ្រង់ព្រះរាជទាននាមថា **វត្តឥន្ទញ្ញាណ** ដោយយកព្រះបព្វជិតនាមនៃសម្តេចព្រះសុធម្មាធិបតី ព្រះនាមដើម **កុល - ទេស** ជាព្រះសង្ឃរាជថ្នាក់ទី ២ នៃគណៈធម្មយុត្តិកនិកាយ ឲ្យជានាមនៃវត្តនេះ ។

វត្តទាំងពីរនេះ បានត្រូវសម្តេចសហជីវិនព្រះប្រមុខរដ្ឋ ទ្រង់ព្រះបញ្ជាឲ្យសហជីវិន **ប៊ុន លាង** ធ្វើការនៅព្រះបរមរាជវាំង ទទួលភារៈចាត់ចែងធ្វើនៅលើផ្ទៃដីមានទំហំ ២,៩៦២៤ហ. នៃទំហំដីក្រុងទាំងមូល ៦៨,៣០ហ. ដោយចំណាយប្រាក់អស់ចំនួន ៤.៩២៨.៤៣០៛០០ ដែលត្រូវបែងចែកស្មើគ្នា សម្រាប់ការស្ថាបនាវត្តទាំងពីរ ដែលក្នុងមុខចំណាយទាំងនេះ មាន ៣.០៦៤.១០៩៛៥០ ជាប្រាក់បានមកពីបុណ្យផ្កា ដែលសម្តេចសហជីវិនព្រះប្រមុខរដ្ឋ ទ្រង់ផ្តួចផ្តើមធ្វើកាលពីថ្ងៃទី ២ កុម្ភៈ ១៩៦២ ក្រៅពីនេះជាប្រាក់ព្រះរាជទ្រព្យផ្ទាល់ព្រះអង្គនៃសម្តេចឪ ។

កិច្ចស្ថាបនាវត្តទាំងពីរនេះ បានត្រូវចាប់ផ្តើមតាំងពីឆ្នាំ ១៩៦២ ហើយបានរួចស្រេចនៅចុង

ឆ្នាំ ១៩៦៣ ដែលត្រូវធ្វើពិធីសម្ពោធឆ្លង - បញ្ចុះខណ្ឌសីមា ក្រោមព្រះអធិបតីភាពដ៏ខ្ពង់ខ្ពស់នៃសម្ដេចសហជីវិនព្រះប្រមុខរដ្ឋ ចំនួន ៥ ថ្ងៃ គឺពីថ្ងៃទី ១៨ ដល់ថ្ងៃទី ២២ វិច្ឆិកា ១៩៦៦ ។

ការប្រតិស្ឋានព្រះពុទ្ធសាសនានៅក្រុងព្រះសីហនុនេះ គឺជាថ្វីព្រះហស្តនៃសម្ដេច **ព្រះនរោត្តម - សីហនុ ឧបយុវរាជ ជាព្រះប្រមុខរដ្ឋ** ដែលព្រះអង្គទ្រង់ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភកដ៏ផ្ដើមនៃជនជាតិខ្មែរ ។

វត្តដ៏រុងរឿងទាំងពីរនេះ ពុំមែនគ្រាន់តែសម្រាប់ធ្វើឲ្យក្រៀវបរទេស បានស្គាល់ច្បាស់នូវទំហំនិងតម្លៃនៃព្រះពុទ្ធសាសនានៅប្រទេសកម្ពុជាប៉ុណ្ណោះទេ, ជាពិសេស បានធ្វើឲ្យឃើញនូវការយកចិត្តទុកដាក់ចំពោះកិច្ចស្ថាបនា ដែលសង្គមរាស្ត្រនិយម មានសម្ដេចសហជីវិនជាព្រះប្រធាន បានបំពេញជាប្រយោជន៍ដល់ពុទ្ធចក្រក៏ដូចជាខាងអាណាចក្រដែរ ។

គួរកត់សំគាល់ថា បន្ទាប់ពីការលើកឋានៈសម្ដេចព្រះសង្ឃនាយកទាំងពីរព្រះអង្គ ជាសម្ដេចព្រះសង្ឃរាជមក សម្ដេចសហជីវិនព្រះប្រមុខរដ្ឋ ទ្រង់បានស្ថាបនាវត្តទាំងពីរនេះឡើង ដើម្បីជាអនុស្សាវរីយ៍នៃការប្រទានកិត្តិយសដ៏ខ្ពង់ខ្ពស់ចំពោះព្រះពុទ្ធសាសនា និងដើម្បីអប់រំយុវជនឲ្យចេះគោរពប្រតិបត្តិព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋ ។

## ពុទ្ធភាសិត

ជាតិប្រាជ្ញនៅជិតបណ្ឌិតប្រាជ្ញ មួយរំពេចក៏អាចចេះធម៌អាថ៌
ដូចអណ្ដាតដឹងរសនៃអាហារ ជួរចត់ខាវហើរប្រែអាចដឹងបាន ។

ធម្មបទដ្ឋកថា ពាលវគ្គ



សម្តេចព្រះមហាសុមេធាធិបតី ជោតញ្ញាណោ (ជួន - ណាត) ព្រះសង្ឃរាជថ្នាក់ទី ១ នៃគណៈមហានិកាយ ទ្រង់ប្រសូតនៅថ្ងៃអង្គារ ១១ រោច ខែផល្គុន ឆ្នាំមមែឆស័ក ព. ស. ២៤២៦ (មីនា ១៨៨៣) ទ្រង់បានទទួលបព្វជ្ជាជាសាមណេរ នៅថ្ងៃ ១៥ កើតខែពិសាខ ឆ្នាំរកាសំរិទ្ធិស័ក ព. ស. ២៤៤០ (ឧសភា ១៨៩៧) ក្នុងព្រះជន្មាយុ ១៥ ឆ្នាំ, ទ្រង់បានបំពេញឧបសម្បទា នៅថ្ងៃ ១៤ កើតខែជេស្ឋ ឆ្នាំរោងឆស័ក ព. ស. ២៤៤៧ (មិថុនា ១៩០៤) ក្នុងព្រះជន្មាយុ ២១ ឆ្នាំ, ទ្រង់បានឡើងសមណស័ក្តិជាព្រះមហាសុមេធាធិបតីព្រះសង្ឃនាយក គ. ស. ១៩៤៨, ជាសម្តេចព្រះមហាសុ-មេធាធិបតីសង្ឃនាយក គណៈមហានិកាយ ក្នុងឆ្នាំ ១៩៥០, ជាសម្តេចព្រះសង្ឃរាជថ្នាក់ទី ១ ក្នុងឆ្នាំ ១៩៦៣, ក្នុងឆ្នាំ ១៩៥៧ រដ្ឋាភិបាលនៃសហភាពភូមា បានប្រគេនព្រះឋានៈសម្តេច ជាព្រះអគ្គមហាបណ្ឌិតនៃសហភាពភូមា, ក្នុងឆ្នាំ ១៩៥៧ បានតម្លើងព្រះឋានៈជាព្រះអភិធជមហារដ្ឋគុរុ នៃសហភាពភូមា ដែលជាសមណស័ក្តិខ្ពស់បំផុតនៃប្រទេសនេះ។





សម្តេចព្រះសុធម្មាធិបតីព្រះសង្ឃរាជថ្នាក់ទី ២ នៃគណៈធម្មយុត្តិកនិកាយ ព្រះនាម ឥន្ទញ្ញាណោ (ត៊ុល-ទេស) ទ្រង់ប្រសូតនៅថ្ងៃអាទិត្យ ១៥ កើតខែស្រាពណ៍ ឆ្នាំថោះត្រីស័ក គ. ស. ១៨៩១, ទ្រង់បានទទួលបព្វជ្ជាជាសាមណេរ នៅថ្ងៃ ៨ កើតខែអាសាធ ឆ្នាំម្សាញ់បញ្ចស័ក គ. ស. ១៩០៥ ក្នុងព្រះជន្មាយុ ១៥ ឆ្នាំ, ទ្រង់បានបំពេញឧបសម្បទា នៅថ្ងៃអាទិត្យ ១៣ កើតខែអាសាធ ឆ្នាំកុរត្រីស័ក គ. ស. ១៩១១ ក្នុងព្រះជន្មាយុ ២១ ឆ្នាំ, ទ្រង់បានទទួលសមណ-ស័ក្តិជាព្រះសុធម្មាធិបតីសង្ឃនាយកស្តីទី និងចៅអធិការវត្តបទុមវតី នៅថ្ងៃទី ៣១ មករា ឆ្នាំមមែសប្តស័ក, ជាសម្តេច សង្ឃនាយកពេញទី នៅថ្ងៃទី ២៨ កុម្ភៈ ឆ្នាំរកអដ្ឋស័ក គ. ស. ១៩៥៧, ជាព្រះសង្ឃរាជថ្នាក់ទី ២ នៃគណៈធម្ម-យុត្តិកនិកាយ នៅថ្ងៃទី ២៨ វិច្ឆិកា ឆ្នាំថោះបញ្ចស័ក គ. ស. ១៩៦៣, ទ្រង់សោយព្រះទិវង្គត នៅថ្ងៃទី ២៧ មេសា ១៩៦៦ ត្រូវនឹងថ្ងៃពុធ ៨ កើតខែពិសាខ ឆ្នាំមមីអដ្ឋស័ក ព. ស. ២៥០៩ ក្នុងព្រះជន្មាយុ ៧៣ ឆ្នាំ វស្សា ៥២ ។

# វត្តជោតញ្ញាណ

## គណៈមហានិកាយ

### នៅក្រុងព្រះសីហនុ



ស្ថាបនាក្នុង ព. ស. ២៥០៤ – គ. ស. ១៩៦២

ដោយចំណាយប្រាក់ ២.៨៦៤.២១៥ រៀល សម្ពោធឆ្លង – បញ្ចុះខណ្ឌសីមា

ពីថ្ងៃសុក្រទី ១៨ ដល់ថ្ងៃអាទិត្យទី ២០ ខែវិច្ឆិកា ១៩៦៦

" *ទិដ្ឋភាពខាងមុខ* "

[illegible]

[illegible]

[illegible]



[illegible]

[illegible]

[illegible]

[illegible]

# វត្តខោតញ្ញាណ

## ស្ថាបនាឡើងតាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់

## នៃសម្តេចព្រះនរោត្តម - សីហនុ ព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍

វត្តនេះ តាំងនៅលើកូនភ្នំមួយជាផ្ចិតនៃទីក្រុង ប្រកបដោយទេសភាពដ៏ប្រសើរ ដែលសម្តេច **ព្រះនរោត្តម សីហនុ ឧបយុវរាជ ជាព្រះប្រមុខរដ្ឋ** ទ្រង់បានស្ថាបនាឡើងតាំងពីឆ្នាំ ១៩៦២ ដល់ឆ្នាំ ១៩៦៣ ដោយចំណាយប្រាក់ ២.៤៦៤.២១៥ រៀល ដែលរួមទាំងតម្លៃព្រះវិហារ និងកុដិ ២ ខ្នងផង ដើម្បីវេរប្រគេនចំពោះព្រះសង្ឃខាងគណៈមហានិកាយ ។

ព្រះវិហារធ្វើពីបេតុងអារម៉េរំលេចដោយក្បូរក្បាច់រចនាតាមប្រពៃណីដ៏ស័ក្តិសម ដែលមានទំហំទទឹង ១១ ម៉ែត្រ បណ្តោយ ១៩ ម៉ែត្រ បានវិចិត្រទិដ្ឋភាពនៃទីក្រុងឲ្យមានលក្ខណៈកាន់តែប្រសើរឡើង ។ ដំបូលបីជាន់នៃព្រះវិហារ ដែលមាននាគ, ជហ្វា, ជងក្តារ, គាងគ្វាយ និងហោជាងដ៏ត្រដែត បានបញ្ចេញនូវភាពសង្ហាររបស់ខ្លួន ជាកិត្តិយសនៃព្រះពុទ្ធបដិមាករអង្គធំ ដែលជាព្រះជ័យ ឬជាព្រះប្រធានដ៏ស័ក្តិសិទ្ធិនៃទីក្រុង ។

ក្រៅពីព្រះវិហារ មានកុដិពីរខ្នងតាមរបៀបអនាម័យ ធ្វើពីឥដ្ឋប្រក់ក្បឿងពណ៌យ៉ាងស្អាត គឺកុដិមួយខ្នងមានទទឹង ៦ ម៉ែត្រ បណ្តោយ ១៥ ម៉ែត្រ ចែកជា ៣ បន្ទប់ គឺបន្ទប់សំណាក់មួយ, បន្ទប់ទទួលភ្ញៀវមួយ និងបន្ទប់សំអាតកាយមួយ ហើយមានរបៀងជាពនហាលដ៏ទូលាយ សម្រាប់ជាទីស្នាក់អាស្រ័យ នៃលោកគ្រូចៅអធិការ ។

កុដិមួយខ្នងទៀត មានបណ្តោយ ៣០ ម៉ែត្រ, ទទឹង ៦ ម៉ែត្រ, ខណ្ឌជា ៥ បន្ទប់ ដែលរួមទាំងបន្ទប់ជម្រះកាយ ព្រមទាំងរបៀងជាពនហាលដ៏វែងផង សម្រាប់ជាលំនៅនៃព្រះសង្ឃបរិស័ទ ។

លេខ ១១៥ - ប.រ.

ចុះថ្ងៃទី ១២ - ២ - ៦៤

# ព្រះរាជក្រឹត្យ

## សម្ដេចព្រះនរោត្ដម - សីហនុ ឧបយុវរាជ

## ជាព្រះប្រមុខរដ្ឋ

បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជអាណាចក្រ,

បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ ៦០១ ប-រ ចុះថ្ងៃទី ៦ តុលា ១៩៦២ កែប្រែនិងបន្ថែមដោយអត្ថបទបន្ទាប់មកទៀត ស្ដីពីការតែងតាំងគណៈរដ្ឋមន្ត្រី,

បានទ្រង់យល់ ព្រះរាជប្រកាសលេខ ៧៩ និង ៦៥ ចុះថ្ងៃទី ២១ វិច្ឆិកា ១៩០៣ និងទី ៦ សីហា ១៩២៩ ដែលកែប្រែដោយព្រះរាជក្រឹត្យលេខ ១៨៨ ន-ស ចុះថ្ងៃទី ៣០ កញ្ញា ១៩៤៩ និងលេខ ៦៤១ ន-ស ចុះថ្ងៃទី ២៨ ធ្នូ ១៩៥៣ បញ្ញត្តអំពីការកសាងវត្ត,

តាមសេចក្ដីក្រាបបង្គំស្នើសុំនៃរដ្ឋលេខាធិការក្រសួងធម្មការ,

គណៈរដ្ឋមន្ត្រីបានយល់ព្រមផង,

### ទ្រង់ត្រាស់បង្គាប់ ដូចមានខាងក្រោមនេះ :

**ប្រការ ១.–** ទ្រង់ប្រកាសថា ការស្ថាបនានៃវត្ត "**ជោតញ្ញាណ**" គណៈមហានិកាយ នៅក្រុងព្រះសីហនុ ត្រូវទទួលការស្គាល់ជាត្រឹមត្រូវដោយអនុលោមទៅតាមបទបញ្ញត្តិ នៃព្រះរាជក្រឹត្យលេខ ៦៤១ ន.ស ចុះថ្ងៃទី ២៨ ធ្នូ ១៩៥៣ ។

**ប្រការ ២.–** រដ្ឋលេខាធិការក្រសួងធម្មការ ត្រូវទទួលភារៈចាត់ការឲ្យបានសម្រេច តាមព្រះរាជក្រឹត្យនេះ ។

ភ្នំពេញ, ថ្ងៃទី ។ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥០៧

ត្រូវនឹងថ្ងៃទី ១២ ខែកុម្ភៈ គ.ស. ១៩៦៤

សម្ដេចទ្រង់ឡាយព្រះហស្តលេខា : **នរោត្ដម - សីហនុ**

បានក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខានៃសម្តេចព្រះប្រមុខរដ្ឋ

រដ្ឋលេខាធិការក្រសួងធម្មការ

ព្រះហស្តលេខា : នរោត្តម - ភូរិស្សារា

ទទួលព្រះរាជបញ្ជា នៃសម្តេចព្រះប្រមុខរដ្ឋ

នាយករដ្ឋមន្ត្រី

ព្រះហស្តលេខា : នរោត្តម - កន្តុល

បានចម្លងដើម្បីចែក :

អគ្គលេខាធិការ នៃគណៈរដ្ឋមន្ត្រី

ហត្ថលេខា : អ៊ុក - ស៊ុន

ក្រសួងដែលត្រូវចម្លងផ្ញើ :

- មន្ទីរឯកសារ រ.អ.ល.គ.រ.
- រ.ក. ក្រុងព្រះសីហនុ
- វត្តសាមីរូប ។

បានចម្លងត្រឹមត្រូវតាមដើមហើយ :

ជ. អនុរដ្ឋលេខាធិការក្រសួងធម្មការ

នាយការិយាល័យធម្មការ

ហត្ថលេខា : មែរ - ប៉ាន់



កុដិសម្រាប់ចៅអធិការ នៃ **វត្តខ្វាតញ្ញាណ** តាមរបៀបអនាម័យ
ដែលមានបន្ទប់សម្រាប់ទទួលភ្ញៀវមួយ បន្ទប់សំណាក់មួយ និងបន្ទប់ជម្រះកាយមួយ

"ទិដ្ឋភាព មើលពីចំហៀង"



យម៉ខែអបប្រាមកេ ណរញ្ញាគ៩៦រក្ត២ ឧាំ កេតឹអខែរប់មៀហស៊ីកុ
យមួយកេះមៀងប់ខ្លួបផឱ យមួផកឹណហំប់ខ្លួប យមួក្ស្រែហខ្លួខប់មៀហប់ខ្លួបឧមេហង៉រី
" ឌៀលាបំតឹហម៉ា ៣គង្គ៉ី "



កុដិសម្រាប់ព្រះសង្ឃបរិស័ទ នៃ **វត្តជោតញ្ញាណ**

មានបន្ទប់ ៥ ដែលរួមទាំងបន្ទប់សម្រាប់ជម្រះកាយផង

" ទិដ្ឋភាព មើលពីចំហៀង "

# វត្តឥន្ទញ្ញាណ

## គណៈធម្មយុត្តិកនិកាយ

## នៅក្រុងព្រះសីហនុ



ស្ថាបនាក្នុង ព. ស. ២៥០៤ – គ. ស. ១៩៦២

ដោយចំណាយប្រាក់ ២.៤៦៤.២១៥ រៀល សម្ពោធឆ្លង – បញ្ចុះខណ្ឌសីមា

ពីថ្ងៃអាទិត្យទី ២០ ដល់ថ្ងៃអង្គារទី ២២ វិច្ឆិកា ១៩៦៦

*" ទិដ្ឋភាព មើលពីខាងក្រោយ "*





កុដិសម្រាប់ចៅអធិការ និងកុដិសម្រាប់បរិស័ទនៃ **វត្តឥន្ទញ្ញាណ**
មានបន្ទប់ជម្រះកាយភ្ជាប់ជាមួយដូចគ្នា



# វត្តឥន្ទញ្ញាណ

## ស្ថាបនាឡើង តាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់
## នៃសម្តេចព្រះនរោត្តម សីហនុ ព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍

វត្តនេះ កសាងឡើងប្រកបដោយទេសភាពគំរូជាទីមនោរម្យ ដែលសម្តេច **ព្រះនរោត្តម - សីហនុ ឧបយុវរាជ ជាព្រះប្រមុខរដ្ឋ** ទ្រង់បានស្ថាបនាឡើងតាំងពីឆ្នាំ ១៩៦២ ដល់ឆ្នាំ ១៩៦៣ ដោយបំណាយប្រាក់ចំនួន ២.៤៦៤.២១៥ រៀល ដែលរួមទាំងតម្លៃព្រះវិហារនិងកុដិ ២ ខ្នងផង, ដើម្បីវេរប្រគេនចំពោះព្រះសង្ឃខាងគណៈធម្មយុត្តិកនិកាយ ។

វត្តនេះ ឋិតនៅជិតទីផ្សារ ហើយមានសាលាបឋមសិក្សានៅក្បែរនោះផង ។ ឯព្រះវិហារ និងកុដិក៏មានលក្ខណៈប្រហាក់ប្រហែលគ្នានឹងព្រះវិហារ និងកុដិនៃ **វត្តជោតញ្ញាណ** ដែរ ។ ការស្ថាបនាវត្តនេះ តាំងពីព្រះវិហារកុដិសម្រាប់ចៅអធិការ កុដិសម្រាប់ព្រះសង្ឃបរិស័ទ ក៏មានលំនាំដូចការស្ថាបនានៅក្នុង **វត្តជោតញ្ញាណ** ខុសគ្នាបន្តិចបន្តួច តែត្រង់ទេសភាពធម្មជាតិ ។

លេខ ៩១៥ - ប.រ.

ចុះថ្ងៃទី ៣ - ៨ - ៦៤

# ព្រះរាជក្រឹត្យ

## សម្តេចព្រះនរោត្តម - សីហនុ ឧបយុវរាជ

## ជាព្រះប្រមុខរដ្ឋ

បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជអាណាចក្រ,

បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ ៦០១ ប-រ ចុះថ្ងៃទី ៦ តុលា ១៩៦២ កែប្រែនិងបន្ថែមដោយអត្ថបទបន្ទាប់មកទៀត ស្តីពីការតែងតាំងគណៈរដ្ឋមន្ត្រី,

បានទ្រង់យល់ ព្រះរាជប្រកាសលេខ ៧៩ និង ៦៥ ចុះថ្ងៃទី ២១ វិច្ឆិកា ១៩០៣ និងទី ៦ សីហា ១៩២៩ ដែលកែប្រែដោយព្រះរាជក្រឹត្យលេខ ១៨៨ ន-ស ចុះថ្ងៃទី ៣០ កញ្ញា ១៩៤៩ និងលេខ ៦៤១ ន-ស ចុះថ្ងៃទី ២៨ ធ្នូ ១៩៥៣ បញ្ញត្តអំពីការកសាងវត្ត,

តាមសេចក្តីក្រាបបង្គំស្នើសុំនៃរដ្ឋលេខាធិការក្រសួងធម្មការ,

គណៈរដ្ឋមន្ត្រីបានយល់ព្រមផង,

### ទ្រង់ត្រាស់បង្គាប់ ដូចមានខាងក្រោមនេះ :

**ប្រការ ១.–** ទ្រង់ប្រកាសថា ការស្ថាបនានៃវត្ត "**ឥន្ទញ្ញាណ**" គណៈធម្មយុត្តិ នៅក្រុងព្រះសីហនុ ត្រូវទទួលការស្គាល់ជាត្រឹមត្រូវដោយអនុលោមទៅតាមបទបញ្ញត្តិ នៃព្រះរាជក្រឹត្យលេខ ៦៤១ ន-ស ចុះថ្ងៃទី ២៨ ធ្នូ ១៩៥៣ ។

**ប្រការ ២.–** រដ្ឋលេខាធិការក្រសួងធម្មការ ត្រូវទទួលភារៈចាត់ការឲ្យបានសម្រេច តាមព្រះរាជក្រឹត្យនេះ ។

ភ្នំពេញ, ថ្ងៃទី ។ ឆ្នាំរោងឆស័ក ព. ស. ២៥០៧

ត្រូវនឹងថ្ងៃទី ៣ សីហា គ. ស. ១៩៦៤

សម្តេចទ្រង់ឡាយព្រះហស្តលេខា : នរោត្តម - សីហនុ

បានក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខានៃសម្តេចព្រះប្រមុខរដ្ឋ
រដ្ឋលេខាធិការក្រសួងធម្មការ
ព្រះហស្តលេខា : នរោត្តម - ភូរិស្សារា

ទទួលព្រះរាជបញ្ជា នៃសម្តេចព្រះប្រមុខរដ្ឋ
នាយករដ្ឋមន្ត្រី
ព្រះហស្តលេខា : នរោត្តម - កន្តុល

បានចម្លងដើម្បីចែក :
អគ្គលេខាធិការ នៃគណៈរដ្ឋមន្ត្រី
ហត្ថលេខា : អ៊ុក - ស៊ុន

ក្រសួងដែលត្រូវចម្លងផ្ញើ :

– មន្ទីរឯកសារ រ.ស.ល.គ.រ.
– រ.ក. ក្រុងព្រះសីហនុ
– វត្តសាមីរូប ។

បានចម្លងត្រឹមត្រូវតាមដើមហើយ :
ជ. អនុរដ្ឋលេខាធិការក្រសួងធម្មការ
ហត្ថលេខា : ច័ន្ទ - សុន

## តម្លៃជាវ

| | |
|---|---|
| ១ ក្បាល | ២៥៛០០ |
| ប្រចាំឆ្នាំ | ៩០៛០០ |

ផ្ញើអាណត្តិប្រៃសណីយ៍ទៅ ៖

លោក **ទា - ប៊ុនឡុង** អគ្គហេរញ្ញិកនៃពុទ្ធិកសមាគម-

កម្ពុជរដ្ឋ នៅវត្តឧណ្ណាលោម ភ្នំពេញ ។

**Monsieur TEA - BOUN LONG Trésorier Général de l'Association des Bouddhistes au monastère d'Unnalom à PHNOM-PENH.**